គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

# សេចក្តីជូនដំណឹង

**គណៈកម្មាធិការខុមហ្វ្រែល** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោកលោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា គណៈកម្មាធិការខុមហ្វ្រែល នឹងរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតស្តីពី "**ការកំណត់តម្រូវការជាអាទិភាពនៅឃុំ សង្កាត់ដាច់ស្រយាល**" ចំនួន ០៧ នៅតាមទីកន្លែងដោយឡែកៗពីគ្នា។

សិក្ខាសាលានេះមានគោលបំណង បង្កើនការយល់ដឹងដល់ម្ចាស់ឆ្នោតអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងបង្កើនឱកាសឱ្យម្ចាស់ឆ្នោតចូលរួមក្នុងការពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំសង្កាត់របស់ខ្លួន ហើយតម្រូវការជាអាទិភាពទាំងនេះ នឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សក្នុងឃុំ។

ខុមហ្វ្រែល នឹងអញ្ជើញវាគ្មិនជាក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណបក្សនយោបាយក្នុងឃុំសង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល ឬប្រធានសហគមន៍ដើម្បីចាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពក្នុងឃុំ សង្កាត់ដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំសម្រាប់ផ្តល់ជូនគណបក្សនយោបាយនិងមន្ត្រីជាប់ឆ្នោតបំពេញ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

**ទីកន្លែង និងកាលបរិច្ឆេទសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត**

| ល.រ | ថ្ងៃខែឆ្នាំរៀបចំ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | រាជធានី/ខេត្ត | ឈ្មោះទំនាក់ទំនង | ទូរសព្ទ |
|---|---|---|---|---|---|---|
| ១ | ១១/១០/២០១១ | ត្បែង | បន្ទាយស្រី | សៀមរាប | **លោក ផល ម៉ុនត** | **០៩២ ៦៧៦ ៩៨១** |
| ២ | ១៣/១០/២០១១ | អូរសារាយ | ត្រាំកក់ | តាកែវ | **អ្នកស្រី សេង សុន្ទរី** | **០១២ ៨៩២ ៤៨៦** |
| ៣ | ១៧/១០/២០១១ | រាំងទិល | កណ្តៀង | ពោធិសាត់ | **អ្នកស្រី ម៉ិន បុប្ផាជាត** | **០៩៧ ៦៨៤ ៤៤៦៨** |
| ៤ | ១៧/១០/២០១១ | រក្សា | រវៀង | ព្រះវិហារ | **អ្នកស្រី លន់ ស៊ីថាន់** | **០១២ ៨៩១ ៦២៧** |
| ៥ | ១៨/១០/២០១១ | ដំរីពួន | ស្វាយអន្ទរ | ព្រៃវែង | **លោក គឹម សុខុម** | **០១៦ ៩៥៩ ២៦៥** |
| ៦ | ១៨/១០/២០១១ | ថ្មក្រោម | ល្វាឯម | កណ្តាល | **កញ្ញា ឡេង ណាវ** | **០៨៩ ៩៦៤ ៣៤៥** |
| ៧ | ៣០/១០/២០១១ | ពាមជីឡាំង | ត្បូងឃ្មុំ | កំពង់ចាម | **លោក ញឹក សុភ** | **០១២ ៦៧៣ ៨៥៧** |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១១*

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

លោកស្រី ៖ **ហេង សុគន្ធា** (០១៧ ៥៨៣ ៨៦៩)

**ទស្សនៈវិស័យ ៖** ដើម្បីឱ្យការបោះឆ្នោតមានសេរី និងយុត្តិធម៌ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ

**Vision :** A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.

P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org